# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: ខ្មែរ អង់គ្លេស និងបារាំង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-Oct-2014, 15:38
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើបន្ទាន់របស់សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំថ្លែងបើក ក្នុងនាមឲ្យក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គីម ម៉េងឃី

ឡោ ជុនធី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

Judge Claudia FENZ

**ផ្ញើជូន៖**

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ិន

សំ សុគង់

វ៉ីន ពៅ

ទី ស្រ៊ីនណា

Emmanuel ALTIT
Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Elodie DULAC
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Michael Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Julien RIVET
Nushin SARKARATI
Beini YE
Mahesh Rai

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

# I. សេចក្តីផ្តើម

១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) ព្យាយាមសុំឲ្យធ្វើការពិចារណាឡើងវិញទៅលើសំណើរបស់ខ្លួន សុំថ្លែងបើកដោយសង្ខេប នៅពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី។ ពួកគេបានអះអាងថា ចាំបាច់ត្រូវមានការពិចារណាលើសំណើរបស់សហមេធាវីនាំមុខចំពោះបញ្ហានេះ ដោយសារតែមានការផ្លាស់ប្តូរទៅតាមកាលៈទេសៈ និងមានការបដិសេធចំពោះសំណើនេះ នឹងបង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ក្រុមរួមដើមបណ្តឹងរដ្ឋប្បវេណី ដែលវាមិនអាចមានប្រសិទ្ធិភាព តាមរយៈការប្តឹងឧទ្ធរណ៍បានឡើយ។

២. មានមូលដ្ឋានគតិយុត្តិរឹងមាំ ដែលគាំទ្រដល់សំណើរបស់សហមេធាវីនាំមុខ ហើយបានផ្តល់ជាគ្រឹះមួយដែលតាមរយៈនេះ បានអនុញ្ញាតជាមូលដ្ឋាន ពិសេសទៅតាមស្មារតីនៃវិធាន ៨៥ នៃវិធានផ្ទៃក្នុង ព្រមទាំងតួនាទី និងផលប្រយោជន៍ពិសេសរបស់ដើមបណ្តឹង ដែលជាភាគីទទួលសិទ្ធិ ចំពោះកិច្ចដំណើរការនីតិវិធី។ អាស្រ័យហេតុនេះសហមេធាវីនាំមុខ ស្នើដល់លោកប្រធាន និងអង្គជំនុំជម្រះ ឲ្យផ្តល់ឱកាសដល់សហមេធាវីនាំមុខ ក្នុងការថ្លែងបើកបឋមដោយសង្ខេប (រយៈពេល ៤៥ នាទី) នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ អំពី៖

a) សមាសភាពនៃក្រុមរួមដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងផលប្រយោជន៍នានា ដែលសហមេធាវីនាំមុខ មានភារកិច្ចត្រូវធ្វើជាតំណាង ក្នុងសំណុំរឿង ០០២/០២

b) វិធីសាស្ត្រដែលដើមបណ្តឹងរដ្ឋប្បវេណីនឹងអនុវត្ត ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ តាមរយៈការគាំទ្រដល់សហព្រះរាជអាជ្ញា ហើយក្នុងពេលជាមួយគ្នានោះ គិតគូរដល់ភាពចាំបាច់នៃការជំនុំជម្រះដែលឆាប់រហ័ស នៅក្នុងបរិបទពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

c) ទស្សនៈ ព្រមទាំងការជួយរួមចំណែកយ៉ាងពិសេស ដែលដើមបណ្តឹងរដ្ឋប្បវេណី គ្រោងនឹងអនុវត្ត សម្រាប់សវនការលើភស្តុតាង ក្នុងសំណុំរឿង ០០២/០២។

# II. ប្រវត្តិនីតិវិធី

៣. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទីពីរ ក្នុងសំណុំរឿង ០០១ បានព្យាយាមសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ផ្តល់ដល់ពួកគេនូវឱកាស ថ្លែងបើកក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ[1]។

៤. នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយផ្អែកជាចម្បងលើមូលដ្ឋានដែលថា សិទ្ធិបែបនេះមិនមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឬក៏ក្នុងវិធានផ្ទៃក្នុងឡើយ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីមិនមានតួនាទីស្វយ័ត ដែលត្រូវធ្វើនៅដំណាក់កាលបើកកិច្ចដំណើរការនីតិវិធីជំនុំជម្រះឡើយ[2]។

៥. នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងករណី ០០២/០១ បានស្នើសុំឲ្យផ្តល់ឱកាស ក្នុងការថ្លែងបើកបឋមដោយសង្ខេប ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី គឺជាការថ្លែងដែលពួកគេលើកឡើងថា ដើម្បីផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនូវសំឡេង ដើម្បីបញ្ចេញពី "ទស្សនៈ និងការព្រួយបារម្ភ" របស់ពួកគេនៅក្នុងកិច្ចដំណើរការនីតិវិធី[3]។

៦. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយផ្អែកលើមូលដ្ឋានដែលថា "មិនមានមូលដ្ឋានច្បាប់នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក្នុងការផ្តល់ឲ្យតាមសំណើរបស់សហមេធាវីឡើយ"[4]

---

[1] សំណើសុំបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងសិទ្ធិរបស់ពួកគាត់ក្នុងការដាក់សេចក្តីសន្និដ្ឋាន នៅក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី,សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E23**, ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៩ ។

[2] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើក ពេលសវនាការលើអង្គសេចក្តី, សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E23/4**, ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩។

[3] សំណើរបស់សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំធ្វើសេចក្តីថ្លែងការណ៍បឋមដោយសង្ខេប ជំនួសមុខឲ្យដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ **E131/4**, ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១, កថាខណ្ឌ ១៧ (បន្ទាប់ពីនេះហៅថា "សំណើទីពីររបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

[4] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំធ្វើការកត់សម្គាល់បឋមត្រួសៗ ជំនួសមុខឲ្យដើមបណ្តឹងរដ្ឋប្បវេណី (E131/4), ឯកសារ **E131/4/1**, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១។

៧. នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ នៅពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី សហមេធាវីនាំមុខជាតិ លោក ពេជ អង្គ បានធ្វើសំណើដោយផ្ទាល់មាត់ទៅអង្គជំនុំជម្រះសាលាដំបូង សុំផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីថ្លែងបើក[5]។ នៅក្នុងសវនាការដដែលនេះ មេធាវីការពារក្តី នួន ជា បានបង្ហាញការគាំទ្ររបស់ខ្លួនចំពោះសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី[6]។ អង្គជំនុំជម្រះបានបដិសេធទៅលើសំណើ[7]។

៨. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ផ្នែកដំបូងនៃសវនាការលើភស្តុតាង ក្នុងសំណុំរឿង ០០២/០២ នឹងចាប់ផ្តើមនៅថ្ងៃទី១៧ ខែ តុលា ឆ្នាំ ២០១៤ ហើយដោយអនុលោមតាមវិធាន ៨៩ស្ទួន នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា នឹងទទួលបានឱកាសថ្លែងបើកដោយសង្ខេប ហើយជនជាប់ចោទ និង/ឬមេធាវីរបស់ពួកគេ នឹងឆ្លើយតបដោយសង្ខេប[8]។

## III. ការពិភាក្សា

៩. សហមេធាវីនាំមុខ សូមយោងទៅដល់ហេតុផលពាក់ព័ន្ធដែលមាននៅក្នុងពាក្យសុំមុនៗ ស្តីពីសេចក្តីថ្លែងការបើក[9]។

### *ក. ការពិចារណាឡើងវិញលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឱ្យមានសេចក្តីថ្លែងការបើកគឺអាចទទួលយកដោយឈរលើមូលដ្ឋានដែលមានការផ្លាស់ប្តូរទៅតាមកាលៈទេសៈ*

១០. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួននឹងមិនយកពាក្យសុំណាមួយមកពិចារណាឡើយ ប៉ុន្តែ "អាចពិចារណាលើបញ្ហាណាមួយជាថ្មី ប្រសិនបើមានការចាំបាច់ដោយសារមានកាលៈទេសៈ

[5] ប្រតិចារឹកសវនាការ, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ E1/14.1, ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៦៨-៦៩។

[6] *ដូចដើងទំព័រខាងលើ,* ទំព័រ ៧៦ (បញ្ជាក់ថា "យើងគិតថា [ដើមបណ្តឹងរដ្ឋប្បវេណី]... គួរទទួលបានឱកាសក្នុងការនិយាយ បើទោះបីជាត្រឹមតែពីរ បីនាទីក៏ដោយ")។

[7] ដូចដើងទំព័រខាងលើ, ទំព័រ ៦៩-៧០។

[8] ដីកាកំណត់កាលបរិច្ឆេទសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/០២, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ E316, ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ (បន្ទាប់ពីនេះហៅថា "ដីកាកំណត់កាលបរិច្ឆេទ")។

[9] *សូមមើល* សំណើទីមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌទី២៤ និងជើងទំព័រលេខ ១៣

ថ្មីកើតឡើង”[10]។ ចាប់ពីពេលចេញសេចក្ដីសម្រេចរបស់ខ្លួន លើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការសុំធ្វើសេចក្ដីថ្លែងការបឋមដោយសង្ខេប អង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយចំនួន ដែលបញ្ជាក់អំពីលក្ខណៈ និងសមាសភាគនៃក្រុមរួមដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២[11]។ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងបានចេញផែនការសម្រាប់ការបើកសវនាការសម្រាប់ករណី០០២/០២[12] ហើយអង្គជំនុំជម្រះតុលាការកំពូលបានផ្ដល់ការបញ្ជាក់យ៉ាងច្បាស់ថា ការជំនុំជម្រះក្ដីនេះ គឺជាការជម្រះក្ដីថ្មីមួយនៅក្នុងសំណុំរឿង ០០២ ដែលត្រូវបានបំបែក[13]។

១១. ដោយយោងតាមការវិវឌ្ឍន៍ទាំងនេះ និងដើម្បីធានានូវការចូលរួមប្រកបដោយអត្ថន័យរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើការនីតិវិធីទាំងនេះ និងគោរពដល់ គោលការណ៍មូលដ្ឋាននៃតម្លាភាព ការចែករំលែកព័ត៌មាន និងសិទ្ធិជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណីសូមលើកឡើងថាវាមានសារៈសំខាន់ដែលថា សហមេធាវីនាំមុខមានឱកាសក្នុងការថ្លែងបើកដោយសង្ខេប ដែលទាក់ទងនឹងតួនាទីជាក់លាក់ និងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើការនីតិវិធីនៃករណី ០០២/០២។

## ខ. ការពិចារណាឡើងវិញ លើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ការថ្លែងបើកសង្ខេប គឺជាការចាំបាច់ ដើម្បីជៀសវាងពីព្យសនកម្មដែលមិនអាចកែប្រែបាន ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី

[10] *សូមមើលឧទាហរណ៍* សេចក្ដីសម្រេចលើសំណើរបស់ខៀវ សំផន សុំពន្យាការចាប់ផ្ដើមសំណុំរឿង ០០២/០២, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, E314/5, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤, កថាខណ្ឌទី៥ និងសេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្ដីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, E238/11/1, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២, កថាខណ្ឌទី៧

[11] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីនេះមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, E284, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣

[12] *សូមមើល*ដីកាកំណត់កាលបរិច្ឆេទ ទំព័រ ២

[13] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ខ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២, សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, E301/9/1/1/3, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤, កថាខណ្ឌ៤២

១២. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ បដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំសិទ្ធិថ្លែងបើកដោយសង្ខេប បង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ក្រុមរួមដើមបណ្តឹងរដ្ឋប្បវេណី ដែលព្យសនកម្មនេះមិនអាចទូទាត់សងបានតាមរយៈបណ្តឹងឧទ្ធរណ៍ឡើយ។ ដូចដែលបានបង្ហាញនៅក្នុងញត្តិនេះ ដើមបណ្តឹងរដ្ឋប្បវេណី មានតួនាទី និងផលប្រយោជន៍ពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក[14] ដែលតួនាទី និងផលប្រយោជន៍នេះមិនត្រូវបានគ្រប់ដណ្តប់ពេញលេញ នៅក្នុងផលប្រយោជន៍ដែលបានជម្រុញ និងតួនាទីដែលបានអនុវត្តដោយសហព្រះរាជអាជ្ញានោះឡើយ។

១៣. លើសពីនេះទៀត វិធានផ្ទៃក្នុងមិនបានចែងពីការប្តឹងសាទុក្ខ ចំពោះបញ្ហានេះ នៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលនេះឡើយ[15] ហើយបានកម្រិតកំណត់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការប្តឹងសាទុក្ខ តែនៅពេលបន្ទាប់ពីចេញសាលក្រមប៉ុណ្ណោះ[16]។ បើទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខបន្ទាប់ពីសាលក្រមត្រូវបានប្រកាស ក៏មិនមានមធ្យោបាយណាមួយអាចទូទាត់សងដោយប្រសិទ្ធិភាពចំពោះព្យសនកម្មដែលបានកើតឡើងរួចទៅហើយនោះឡើយ ព្រោះឱកាសក្នុងការថ្លែងបើកបឋម បានបាត់បង់ដោយមិនអាចកែប្រែបាន។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងថា នេះគឺជាភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការផ្តល់ជូនការពិចារណាឡើងវិញលើបញ្ហានេះ ហើយនឹងចេញសេចក្តីសម្រេចមួយ មុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/០២ ដើម្បីជៀសផុតពីព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះដើមបណ្តឹងរដ្ឋប្បវេណី នៃកិច្ចដំណើរការនីតិវិធីទាំងនេះ។

---

[14] *សូមមើលជាឧទាហរណ៍ នៅខាងក្រោម* ត្រង់កថាខណ្ឌ ១៨ -១៩, ២៤ និង ២៨-២៩។

[15] វិធាន ១០៤ នៃវិធានផ្ទៃក្នុង(កំណែលើកទី ៨), អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១១(បន្ទាប់ពីនេះហៅថា "វិធានផ្ទៃក្នុង"), (ចែងថា បណ្តឹងសាទុក្ខនៅដំណាក់កាលជំនុំជម្រះ អាចធ្វើឡើងចំពោះបញ្ហា ដូចតទៅ៖ ("ក. សេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី, ខ. សេចក្តីសម្រេចអំពី ការឃុំខ្លួន និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យ តាមផ្លូវតុលាការ អនុលោមតាមវិធាន ៨២, គ. សេចក្តីសម្រេចអំពីវិធានការការពារតាមវិធាន ២៩(៤)(គ) និង ឃ. សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ តាមវិធាន ៣៥(៦)" និងបញ្ហាដទៃផ្សេងទៀតដែលត្រូវដោះស្រាយបន្ទាប់ពីចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។)

[16] វិធាន ១០៥ នៃវិធានផ្ទៃក្នុង (ដោយចែងពីលក្ខខណ្ឌនៃសិទ្ធិប្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង (ទៅលើបញ្ហាក្រៅពីសំណង) បើទោះបីជាសហព្រះរាជអាជ្ញា ដាក់បណ្តឹងសាទុក្ខ ឬអត់ក៏ដោយ)

***គ. ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាជនរងគ្រោះដែលសិទ្ធិរបស់ពួកគេចាំបាច់ត្រូវទទួលបានការគោរព ក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់ នៅចំពោះមុខ អ.វ.ត.ក***

១៤. ដូចដែលបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមរបស់វិធានផ្ទៃក្នុង ពាក្យ"ដើមបណ្ដឹងរដ្ឋប្បវេណី" សំដៅលើ "**ជនរងគ្រោះ** ដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួន ត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ ដោយយោងទៅលើវិធានផ្ទៃក្នុងនេះ"[17]។

១៥. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា "ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង**ជនរងគ្រោះ**"[18]។ វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុងបានចែងបន្ថែមថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា សិទ្ធិរបស់ជនរងគ្រោះ [...] ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្ដី"[19]។

***ឃ. ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាភាគីពេញលេញនៃកិច្ចដំណើរការនីតិវិធី ដែលសិទ្ធិរបស់ពួកគេត្រូវទទួលបានការយកចិត្តទុកដាក់ និងការពារដោយអង្គជំនុំជម្រះសាលាដំបូង។***

១៦. ដូចដែលបានបញ្ជាក់នៅក្នុងសទ្ទានុក្រមរបស់វិធានផ្ទៃក្នុង "ភាគីសំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី"[20]។ ជាការពិត នៅអ.វ.ត.ក ដើមបណ្ដឹងរដ្ឋប្បវេណីមានឋានៈស្មើគ្នានឹងសហព្រះរាជអាជ្ញា និងជនជាប់ចោទ ហើយពួកគេទទួលបានសិទ្ធិនីតិវិធីក្នុងទ្រង់ទ្រាយធំ ដែលភ្ជាប់ជាមួយនឹងឋានៈជាភាគី ក្នុងនោះរួមមានដូចជា៖ សិទ្ធិបង្ហាញភស្ដុតាង[21] សិទ្ធិស្នើសុំ និងពិនិត្យលើសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី[22] ព្រមទាំងសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[23]។

---

[17] វិធានផ្ទៃក្នុង, *ទំព័រ ៨០* (ដោយមានការគូសបញ្ជាក់បន្ថែម)។

[18] វិធាន ២១(១) នៃវិធានផ្ទៃក្នុង *(ដោយមានការគូសបញ្ជាក់បន្ថែម)*។

[19] វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង *(ដោយមានការគូសបញ្ជាក់បន្ថែម)*។

[20] សទ្ទានុក្រម, វិធានផ្ទៃក្នុង, ទំព័រ ៨១ *(ដោយមានការគូសបញ្ជាក់បន្ថែម)* ។

[21] វិធាន ៨០ និង ៨៧ នៃវិធានផ្ទៃក្នុង។

១៧. បន្ថែមលើនេះ វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុងបានកំណត់កាតព្វកិច្ចវិជ្ជមានរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាថា "ដំណើរការនីតិវិធីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិ របស់ភាគីទាំងឡាយ"[24]។

## *ង. តួនាទី និងការចូលរួមចំណែកជាពិសេសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធី តម្រូវឱ្យពួកគេមានឱកាសថ្លែងបើកដោយសង្ខេប។*

១៨. ក្នុងខណៈពេលដែលតួនាទីរបស់ព្រះរាជអាជ្ញាគឺអនុវត្តបណ្ដឹងអាជ្ញា តាមរយៈ "ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយណា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[25] នោះតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់អ.វ.ត.ក គឺ "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយគាំទ្រដល់ការចោទប្រកាន់" និងស្វែងរកសំណង[26]។ ពាក់ព័ន្ធនឹងតួនាទីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការ "គាំទ្រ" ចាំបាច់ត្រូវបកស្រាយក្នុងន័យនៃការគាំទ្រដល់សកម្មភាពចោទប្រកាន់ (ឧទាហរណ៍ បណ្ដឹងអាជ្ញា) មិនមែនគាំទ្រដល់ព្រះរាជអាជ្ញានោះទេ[27]។ ដូចដែលនឹងពិភាក្សានៅផ្នែកខាងក្រោម ការពិភាក្សានេះទើបជាការបកស្រាយតែមួយគត់ដែលសមហេតុផលចំពោះវិធាន ដោយអនុលោមតាមអាណត្តិការងាររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងផលប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី។

១៩. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានផ្ដល់ឱ្យនូវអាណត្តិការងារ *ជាក់លាក់* ដើម្បី "តំណាងឱ្យផលប្រយោជន៍របស់បណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ"[28] ដែលផ្ទុយពីសហព្រះរាជអាជ្ញា ដែលមានតួនាទីតំណាងឱ្យ "ផលប្រយោជន៍*ទូទៅ*របស់

---

[22] វិធាន ៩១(២)នៃវិធានផ្ទៃក្នុង។

[23] វិធាន ៩៤ នៃវិធានផ្ទៃក្នុង។

[24] វិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង *(ដោយមានការគូសបញ្ជាក់បន្ថែម)*។

[25] វិធាន ៤៩ នៃវិធានផ្ទៃក្នុង។

[26] វិធាន ២៣ នៃវិធានផ្ទៃក្នុង ។

[27] ជាការគួរឱ្យកត់សម្គាល់, មានចន្លោះតិចតួចសម្រាប់ការជជែកដេញដោល នៅពេលដែលធ្វើការប្រៀបធៀបរវាងវិធានជាភាសាបារាំង និងភាសាអង់គ្លេស ដែលការយោងគឺមិនមែនសំដៅទៅលើការិយាល័យ ឬអង្គភាពដែលមានតួនាទីចោទប្រកាន់ឡើយ ប៉ុន្តែគឺសំដៅទៅលើសកម្មភាពចោទប្រកាន់ "soutien à l'accusation." ដូចដើងទំព័រខាងលើ។

[28] វិធាន ១២ស្ទួនពីរ(៥)(ក) នៃវិធានផ្ទៃក្នុង។

សង្គម" គឺក្រុមមួយដែលជនរងគ្រោះត្រូវបានចាត់ទុកថា ស្ថិតក្នុងនោះ ក្នុងចំណោមអ្នកដទៃផ្សេងទៀតទាំងអស់[29]។ ចំណុចមួយដែលអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់បានបញ្ជាក់យ៉ាងច្បាស់ក្នុងការកត់សម្គាល់គឺ "ព្រះរាជអាជ្ញាតំណាងឲ្យសហគមន៍ មិនមែនតំណាងឲ្យបុគ្គល ឬផលប្រយោជន៍ផ្នែកណាមួយនោះទេ"[30]។ អង្គជំនុំជម្រះបានទទួលស្គាល់បន្ថែមទៀតអំពី លក្ខណៈពិសេសរបស់បណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ដោយបង្ហាញពីភាពខុសគ្នារវាងតួនាទីដើមបណ្ដឹងរដ្ឋប្បវេណី ជាមួយនឹងតួនាទីរបស់ព្រះរាជអាជ្ញា ដោយការកត់សម្គាល់ថា "ភាគីនីមួយៗមានតួនាទីខុសៗគ្នា នៅក្នុងការរក្សាផលប្រយោជន៍ និងការទទួលខុសត្រូវជាពិសេសរបស់ខ្លួននៅក្នុងការជំនុំជម្រះក្ដី"[31]។

២០. ហេតុដូច្នេះ សំណើរបស់សហមេធាវីនាំមុខមិនមែនស្វះស្វែងដើម្បីទទួលបានសិទ្ធិដូចគ្នា ក្នុងការថ្លែងបើក ដូចដែលបានផ្ដល់ជូនទៅភាគីដទៃឡើយ ហើយសំណើនេះក៏មិនមែនព្យាយាមដណ្ដើម ឬអនុវត្តជាន់គ្នានូវតួនាទីរបស់អយ្យការនោះឡើយ។ ដូចដែលបានរៀបរាប់ក្នុងញត្តិនេះ ខ្លឹមសារដែលបានស្នើឡើងសម្រាប់សេចក្ដីថ្លែងបើក របស់សហមេធាវីនាំមុខ រៀបរាប់លម្អិតអំពីគោលដៅ និងការរួមចំណែកយ៉ាងពិសេស នៅក្នុងកិច្ចដំណើរការនីតិវិធី ដែលពួកគេប្រមើលមើលថា សេចក្ដីថ្លែងបើកនេះនឹងសម្រេចបាន។ សហមេធាវីនាំមុខព្យាយាមធានាឲ្យបាននូវឱកាសសម្រាប់ការថ្លែងនៅពេលចាប់ផ្ដើមសវនាការ គឺដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីដើរតួនាទីយ៉ាងពិសេស ហើយមានចំណាប់អារម្មណ៍ចំពោះកិច្ចដំណើរការនីតិវិធីនេះ លើសពី "ចំណាប់អារម្មណ៍ទូទៅ" របស់សាធារណជន ដែលចំណាប់អារម្មណ៍នេះ ផ្ដោតសំខាន់ទៅលើផលប្រយោជន៍ជាក់លាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ។

## ច. *លក្ខណៈទ្វេនៃបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក តម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានឱកាស ក្នុងការថ្លែងបើកដោយសង្ខេប។*

[29] សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្ដីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស, សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ២០។

[30] ដូចជើងទំព័រខាងលើ, កថាខណ្ឌ ២១។

[31] *សូមមើល ជាឧទាហរណ៍* ដូចជើងទំព័រខាងលើ, កថាខណ្ឌ ២៧។

២១. ដូចដែលមានចែងនៅក្នុងវិធាន ២៣(១) នៃវិធានផ្ទៃក្នុង គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺដើម្បី៖ "ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ [...] ដោយគាំទ្រដល់ការចោទប្រកាន់ ***និង*** ខ) ទាមទារសំណងផ្លូវចិត្ត និងសមូហភាព [...]"[32]។ បើទោះបីជាសហមេធាវីនាំមុខមានឱកាស ផ្តល់នូវលក្ខណៈពិសេសបឋមនៃខ្លឹមសាររបស់សំណង ដែលពួកគេព្យាយាមទាមទារក៏ដោយ ក៏ការបដិសេធមិនផ្តល់ឱកាសដល់ពួកគេ ក្នុងការថ្លែងបើក គឺជាការបដិសេធមិនផ្តល់ឱកាសដល់ពួកគេ ក្នុងការពន្យល់អំពីវិធីសាស្ត្រដែលពួកគេមានបំណងក្នុងការចូលរួម ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងសំណុំរឿង ០០២/០២ ដែលជាគោលដៅមួយផ្សេងទៀត ដែលសំខាន់ដូចគ្នាសម្រាប់អាណត្តិការងាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលក្ខណៈទ្វេ នៅចំពោះមុខ អ.វ.ត.ក។

***គ. ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាធារណជន ទទួលបានសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបានព័ត៌មានអំពីកិច្ចដំណើរការនីតិវិធី និងបណ្តឹងរដ្ឋប្បវេណី ក្នុងលក្ខណៈមួយដែលឆ្លើយតបយ៉ាងជាក់ច្បាស់ទៅនឹងចំណាប់អារម្មណ៍ជាពិសេសរបស់ពួកគេ។***

២២. វិធាន ២១ នៃវិធានផ្ទៃក្នុងបានចែងអំពីគោលការណ៍ជាមូលដ្ឋានដែលធានាដល់ សច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី[33] ហើយថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន [...] តាមរយៈដំណើរការនីតិវិធី"[34]។ អង្គជំនុំជម្រះខ្លួនឯងផ្ទាល់ក៏បានសង្កត់ធ្ងន់ទៅលើគោលការណ៍ទាំងនេះដែរ តាមរយៈយន្តការពិសេសរបស់ខ្លួន ដូចជា "សវនាការលើឯកសារគន្លឹះ" ដែលអង្គជំនុំជម្រះបានផ្តល់យុត្តិកម្មផ្អែកលើមូលដ្ឋាននៃការផ្តល់ឱ្យនូវ "វិធានការណ៍ជាចម្បង សម្រាប់គណនេយ្យភាពសាធារណ" សម្រាប់កិច្ចដំណើរការនីតិវិធីជំនុំជម្រះ"[35]។ មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានរំឭកបន្ថែមថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈ និងបើកចំហរសម្រាប់តំណាងរបស់រដ្ឋបរទេស តំណាងរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជន តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅ

---

[32] វិធាន ២៣(១) នៃវិធានផ្ទៃក្នុង *(ដោយមានការគូសបញ្ជាក់បន្ថែម)*។

[33] វិធាន ២១(១) នៃវិធានផ្ទៃក្នុង *(ដោយមានការគូសបញ្ជាក់បន្ថែម)*។

[34] វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង *(ដោយមានការគូសបញ្ជាក់បន្ថែម)*។

[35] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង៖ ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២), សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ, ឯកសារ E170, ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ២។

រដ្ឋាភិបាលជាតិ និងអន្តរជាតិ"[36]។ លើសពីនេះទៀត ដូចដែលបានបញ្ជាក់នៅលើគេហទំព័រ អ.វ.ត.ក អង្គជំនុំជម្រះខ្លួនឯងផ្ទាល់បានអះអាងថា "*ការកាត់ក្តីនេះគឺសម្រាប់ប្រជាជនកម្ពុជា*"[37]។

២៣. ដោយសរុបជារួម សហមេធាវីនាំមុខអះអាងថា សនិទានភាពជាមូលដ្ឋានដ៏សំខាន់សម្រាប់គោលការណ៍ និងការអនុវត្តទាំងអស់នេះ គឺដើម្បីធានាជាអតិប្បរមានូវឥទ្ធិពលជាវិជ្ជមានរបស់ អ.វ.ត.ក និងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ចំពោះសាធារណជន តាមរយៈការផ្តល់នូវយុត្តិធម៌ដែលត្រឹមត្រូវ នឹងមានប្រសិទ្ធិភាព ព្រមទាំងធានានូវធម្មានុរូបភាពនៃកិច្ចដំណើរការនីតិវិធី និងផ្តល់ជាអតិប្បរមានូវផលប្រយោជន៍ក្នុងការស្តារឡើងវិញ[38] ដល់ដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

២៤. លើសពីនេះទៀត សហមេធាវីនាំមុខសូមលើកឡើងថា ចំណុចដែលមិនអាចជៀសវាងបាន ក្នុងការលើកកម្ពស់តម្លាភាព ការជូនដំណឹងដល់ជនរងគ្រោះ និងការដឹងឮយ៉ាងពេញលេញអំពីសក្តានុពលនៃការចូលរួមរបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនេះ គឺដើម្បីធានាថាតួអង្គដែលទទួលបានភារកិច្ចយ៉ាងជាក់លាក់ ក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺសហមេធាវីនាំមុខនោះ ត្រូវបានអនុញ្ញាតឱ្យផ្តល់ដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ព្រមទាំងសាធារណជន អំពីលក្ខណៈដែលពួកគេប្រមើលមើលថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះ ផលប្រយោជន៍ដែលសហមេធាវីនាំមុខត្រូវតំណាង និងទស្សនទានដែលពួកគេត្រូវយកមកអនុវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី។

២៥. ការផ្តល់ឱ្យដល់សហមេធាវីនាំមុខនូវឱកាសក្នុងការអន្តរាគមន៍ដោយសង្ខេប នៅក្នុងពេលវេលាដែលសំខាន់បំផុត និងមានការតាមដានយ៉ាងជិតដិតបំផុត ក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះនោះ គឺអង្គជំនុំជម្រះបានបញ្ជូនសារយ៉ាងច្បាស់មួយទៅកាន់សាធារណជន ដើមបណ្តឹងរដ្ឋប្បវេណី ព្រម

---

[36] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ដែលបានវិសោធនកម្ម), ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤។

[37] មាននៅក្នុង: http://www.eccc.gov.kh/en/faq/who-can-attend-trials (ចូលមើលនៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤)។

[38] មូលដ្ឋានសម្រាប់ទស្សនទាននៃការស្តារឡើងវិញ ដែលជាបេសកកម្មរបស់ អ.វ.ត.ក មាននៅក្នុងទាំងការដាក់បញ្ចូលសំណងទៅក្នុងអាណត្តិការងាររបស់តុលាការ និងនៅក្នុងបុព្វកថានៃកិច្ចព្រមព្រៀង ដែលទទួលស្គាល់ "ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ *ការបង្រួបបង្រួមជាតិ* ស្ថេរភាព សន្តិភាព និងសន្តិសុខ" *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣, ទំព័រ ១ ដំណោះស្រាយលេខ 57/228B នៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិ*(ដោយមានការគូសបញ្ជាក់បន្ថែម)*។

ទាំងជនរងគ្រោះថា បទពិសោធន៍ដែលជនរងគ្រោះ ត្រូវបានទទួលស្គាល់ ហើយការចូលរួមរបស់ពួកគាត់ត្រូវបានផ្តល់នូវតម្លៃ។ ជាឧទាហរណ៍ សារដែលត្រូវបញ្ជូន នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល ចាប់ផ្តើមដោយវត្តមាន ឬអវត្តមាននៃការព្រួយបារម្ភណ៍ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះនៅពេលចាប់ផ្តើមសវនាការ ពិតជានឹងជះឥទ្ធិពលដល់ទស្សនទានរបស់ពួកគេ អំពីតម្លៃដែលឋិតនៅក្នុងការចូលរួមរបស់ពួកគេក្នុងកិច្ចដំណើរការនីតិវិធី ហើយនឹងជះឥទ្ធិពលផងដែរដល់ផលប្រយោជន៍ផ្នែកសំណង ដែលកិច្ចដំណើរការនីតិវិធីអាចផ្តល់ដល់ពួកគេ ឬសង្គមជាតិ[39]។ ទស្សនទានអំពីការផ្តល់តម្លៃរបស់តុលាការ ចំពោះការព្រួយបារម្ភណ៍របស់ពួកគេ ក៏ជះឥទ្ធិពលផងដែរដល់បញ្ហាថាតើ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាធារណជន យល់ឃើញថាកិច្ចដំណើរការនីតិវិធីនេះស្របច្បាប់ ដែរឬយ៉ាងណា។

### *ជ. ស្មារតីនៃវិធាន ៨៥ នៃវិធានផ្ទៃក្នុង បង្ហាញថា លោកប្រធាន ដោយពិភាក្សាជាមួយចៅក្រមអង្គជំនុំជម្រះសាលាដំបូងផ្សេងទៀត មានអំណាចឆន្ទានុសិទ្ធិក្នុងការផ្តល់តាមសំណើរបស់សហមេធាវីនាំមុខ។*

២៦. វិធាន៨៥ នៃវិធានផ្ទៃក្នុង ផ្តល់ដល់ប្រធានអង្គជំនុំជម្រះសាលាដំបូង នូវឆន្ទានុសិទ្ធិយ៉ាងសំខាន់ ក្នុងការដំណើរការសវនាការ។ ឆន្ទានុសិទ្ធិនេះរួមបញ្ចូលទាំងកាតព្វកិច្ច "ធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឱ្យប្រព្រឹត្តទៅបានដោយសេរី" ព្រមទាំងដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត មានអំណាច "បដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត"[40]។ សហមេធាវីនាំមុខលើកឡើងថា ស្មារតីនៃវិធានដែលផ្តល់នូវឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ដល់អង្គជំនុំជម្រះក្នុងការពិនិត្យមើលលើដំណើរការសវនាការ ព្រមទាំងសង្កត់ធ្ងន់ទៅលើទំនាក់ទំនងរវាងដំណើរការសវនាការ និងការស្វែងរកការពិតនេះ បានផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់អង្គជំនុំជម្រះ អាចសម្រេចផ្តល់ទៅតាមសំណើរសុំរបស់សហមេធាវីនាំមុខបាន

[39] ចំណុចនេះផ្អែកលើគោលការណ៍ដែលថា ជាពិសេសនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មជាទ្រង់ទ្រាយធំ ការទូទាត់សំណង និងលទ្ធផលនៃការស្តារឡើងវិញ ត្រូវសម្រេចបានមិនមែនត្រឹមតែតាមរយៈការសម្រេចផ្តល់ឱ្យតាមសំណើទាមទារសំណងនៅចុងបញ្ចប់នៃកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ (ដោយសន្មតថាអាចឈានដល់ចំណុចនេះ) ប៉ុន្តែក៏អាចសម្រេចបានផងដែរតាមរយៈកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌផ្ទាល់។ នេះគឺជាសមិទ្ធកម្មដែលលេចធ្លោយ៉ាងខ្លាំង សម្រាប់ការចូលរួមយ៉ាងខ្លាំងក្លារបស់ជនរងគ្រោះ នៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការសិទ្ធិមនុស្សអន្តរជាតិ។

[40] វិធាន ៨៥ នៃវិធានផ្ទៃក្នុង។

## IV. សេចក្តីសន្និដ្ឋាន

២៧. សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងលើ សហមេធាវីនាំមុខសូមលើកឡើងថា ដើម្បីផលប្រយោជន៍យុត្តិធម៌ តម្រូវឲ្យសហមេធាវីនាំមុខទទួលបាននូវឱកាស ក្នុងការថ្លែងបើកដោយសង្ខេប។ តាមរយៈការផ្តល់ឲ្យតាមសំណើនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងនឹង៖

a) ការពារនូវផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ព្រមទាំងធានាថាសិទ្ធិរបស់ពួកគេត្រូវបានគោរព នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងស្រុង

b) ទទួលស្គាល់ថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាភាគីស្វយ័តមួយ ដែលខុសប្លែកពីសហព្រះរាជអាជ្ញា

c) អនុញ្ញាតឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញនូវទេ្វភាពនៃបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខ អ.វ.ត.ក តាមរយៈការបង្ហាញពីវិធីសាស្ត្រដែលពួកគេមានគ្រោងប្រើប្រាស់សម្រាប់ការចូលរួមក្នុងកិច្ចដំណើរការនីតិវិធីលើភស្តុតាង ដោយលើកឡើងពីទស្សនៈទាន និងការចូលរួមយ៉ាងពិសេស ក្នុងការស្វែងរកការពិត

d) បង្កើនធម្មានុរូប និងប្រយោជន៍នៃសំណាង របស់កិច្ចដំណើរការនីតិវិធី សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងសាធារណជន។

២៨. ជាចុងក្រោយ នៅក្នុងបរិបទទាំងមូលនៃកិច្ចដំណើរការនីតិវិធី ពេលវេលាដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំថ្លែងបើកដោយសង្ខេប ដែលមានត្រឹម៤៥នាទី នឹងមិនបង្កជាការពន្យារពេលវេលាដោយមិនសមហេតុផល ចំពោះរដ្ឋបាលតុលាការដែលឆាប់រហ័ស នៅក្នុងសំណុំរឿង ០០២/០២ឡើយ។

## V. សំណើ

អាស្រ័យហេតុនេះ ដើមបណ្តឹងរដ្ឋប្បវេណីសូមស្នើដោយក្តីគោរព សុំឲ្យលោកប្រធាន ដោយមានការពិភាក្សាជាមួយចៅក្រមដទៃទៀតនៃអង្គជំនុំជម្រះសាលាដំបូង និងដោយប្រើប្រាស់ឆន្ទានុសិទ្ធិដែលមានចែងក្នុងវិធាន ៨៥ នៃវិធានផ្ទៃក្នុង៖

- ទទួលយកសំណើបន្ទាន់នេះ និង

- សម្រេចផ្តល់តាមសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងបើកដោយសង្ខេបនៅថ្ងៃដំបូងនៃសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/០២។

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៤ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |